ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## មិនមានករណីជាសះស្បើយ និងមានករណីសង្ស័យវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០១នាក់
## នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ- ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២៧៤នាក់** (ស្មើនឹង ៩៩,៦៤% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៥៤នាក់ និងបុរស ២២០នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៧៥នាក់** (ស្ត្រី ៥៤នាក់ និងបុរស ២២១នាក់)
- អ្នកកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **០១នាក់** ។

**២. ករណីជាសះស្បើយ ៖** មិនមានអ្នកជាសះស្បើយ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

**៣. ករណីសង្ស័យវិជ្ជមានវីរុសកូវីដ-១៩ ៖**

មានករណីសង្ស័យវិជ្ជមានវីរុសកូវីដ-១៩ ថ្មី នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ចំនួន ០១នាក់ (គឺជាបុរសជនជាតិហុងគ្រី អាយុ ៧០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅភូមិត្រស ឃុំស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប) ដែលបានរាយការណ៍ដោយមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប។ បុរសរូបនេះ ជាអ្នកធ្វើដំណើរពីប្រទេសបារាំង បន្តជើងហោះហើរតាមប្រទេសកូរ៉េខាងត្បូង បានមកដល់កម្ពុជានៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០ ហើយលទ្ធផលតេស្តរបស់គាត់នៅពេលនោះ គឺអវិជ្ជមានវីរុសកូវីដ-១៩។ បន្ទាប់មកគាត់ត្រូវបានបន្តធ្វើចត្តាឡីស័កនៅកន្លែងស្នាក់នៅរបស់គាតមអាសយដ្ឋានខាងលើនេះ នៅខេត្តសៀមរាប រហូតដល់ថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ករបស់គាត់ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ការធ្វើតេស្តឡើងវិញក៏បានបង្ហាញលទ្ធផលសង្ស័យថា វិជ្ជមានវីរុសកូវីដ-១៩ ហើយហើយវត្ថុសំណាករបស់គាត់ត្រូវបានបញ្ជូន (មកដល់នៅវេលាយប់ម៉ោងប្រហែលជា ១១:០០ យប់ នៃថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០) ធ្វើការវិភាគបញ្ជាក់នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ ហើយការវិភាគរបស់វិទ្យាស្ថាននេះ នឹងធ្វើនៅវេលាព្រឹកនៃថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ រីឯលទ្ធផលរំពឹងថានឹងអាចទទួលបាននៅល្ងាចនៃថ្ងៃដដែល

សូមជម្រាបជូនថា ទន្ទឹមនឹងពេលនៃការបញ្ជូនវត្ថុសំណាក និងរង់ចាំការវិភាគបញ្ជាក់លើភាពវិជ្ជមានវីរុសកូវីដ-១៩ ពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ ស្រាប់តែក្រុមការងារនៃមន្ទីរសុខាភិបាលខេត្តសៀមរាប មិនអាចទាក់ទងជាមួយបុរសរូបនេះបានឡើយ ដោយបុរសខាងលើនេះ បានរត់គេចចេញពីកន្លែងស្នាក់នៅខាងលើរបស់គាត់បាត់តែម្តង។ បច្ចុប្បន្ន អាជ្ញាធរមានសមត្ថកិច្ចខេត្តសៀមរាប កំពុងព្យាយាមរុករកបុរសជនជាតិហុងគ្រីរូបនេះ តែមិនទាន់រកឃើញនៅឡើយទេ។


ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ប្រសិនបើនៅល្ងាចនៃថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០នេះ លទ្ធផលវិភាគវត្ថុសំណាករបស់គាត់ ពិតជាឃើញថាមានវីរុសកូវីដ-១៩ មែននោះ ស្ថានភាពគេចវេសរបស់គាត់បែបនេះ (តាំងពីម៉ោងប្រហែលជា ៩យប់នៃថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ រហូតមកទល់ពេលនេះ) និងអាចមានហានិភ័យឆ្លងដល់សហគមន៍ បើគាត់ធ្វើដំណើរច្រើន និងជួបមនុស្សច្រើន។ ក្រុមឆ្លើយតបបន្ទាន់ និងធ្វើការស្រាវជ្រាវភ្លាមៗ នៅពេលរកឃើញបុរសនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប ហើយប្រសិនបើមានលោកអ្នកណាបានឃើញ ឬដឹងព័ត៌មានអំពីបុរសជនជាតិហុងគ្រីអាយុ ៧០ឆ្នាំនេះ សូមលោកអ្នក មេត្តាជួយផ្តល់ព័ត៌មានឲ្យបានឆាប់ជាទីបំផុតមកអាជ្ញាធរមានសមត្ថកិច្ច (មានការអំពាវនាវស្រាវជ្រាវរករបស់អធិការដ្ឋានស្នងការនគរបាលក្រុងសៀមរាបតាំងពីយប់មិញ) ឬតាមលេខ ១១៥ ឬតាមលេខទូរស័ព្ទខាងក្រោមនេះ ដើម្បីក្រសួង អាចចាត់វិធានការសុខាភិបាល បានទាន់ពេលវេលា ហើយបងប្អូនដែលបានប៉ះពាល់ជាមួយបុរសខាងលើនេះ សូមចូលរួមមកបង្ហាញខ្លួននៅមន្ទីរសុខាភិបាលខេត្តសៀមរាប ដើម្បីធ្វើតេស្តរកវីរុសកូវីដ-១៩ ដើម្បីរួមគ្នាអាចនឹងបញ្ចៀសបាននូវការចម្លងចូលសហគមន៍។

ក្រសួងសុខាភិបាល សូមធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមបន្តចូលរួមអនុវត្តន៍វិធានការការពារការចម្លងវីរុសកូវីដ-១៩ ទៅតាមការណែនាំ និងការអំពាវនាវជារឿយៗរបស់ក្រសួង ដើម្បីសុខភាពរបស់លោកអ្នក របស់ក្រុមគ្រួសារលោកអ្នក និងការពារការចម្លងចូលក្នុងសហគមន៍យើងផងដែរ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ៩កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា


ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩